# អត្ថប្រយោជន៍លើកលែង
# បុព្វលាភធានារ៉ាប់រង




**Waiver of Premium**

## លក្ខណៈនៃផលិតផល

| | |
|---|---|
| អាយុអ្នកត្រូវបានធានារ៉ាប់រង | 18 - 60ឆ្នាំ |
| រយៈពេលធានារ៉ាប់រង | 5 - 30ឆ្នាំ |

## អត្ថប្រយោជន៍ធានារ៉ាប់រង

ជម្រើសទាំង៣នៃអត្ថប្រយោជន៍លើកលែងបុព្វលាភធានារ៉ាប់រង៖

### ជម្រើសទី១

ករណីអ្នកត្រូវបានធានារ៉ាប់រងមានជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់

ក្រុមហ៊ុននឹងលើកលែងនូវការបង់បុព្វលាភធានារ៉ាប់រង ចាប់ពីកាលបរិច្ឆេទត្រូវបង់បុព្វលាភបន្ទាប់ នៅពេលដែលអ្នកត្រូវបានធានារ៉ាប់រងធ្វើរោគវិនិច្ឆ័យ រកឃើញ/ការវះកាត់ដាក់ស្ដែងនូវជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់ ណាមួយដូចបានចែងក្នុងខ និងលក្ខខណ្ឌនៃបណ្ណសន្យារ៉ាប់រង។



## ជម្រើសទី២

ករណីអ្នកត្រូវបានធានារ៉ាប់រងមានជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់
ឬទទួលរងពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍

ក្រុមហ៊ុននឹងលើកលែងនូវការបង់បុព្វលាភធានារ៉ាប់រង
ចាប់ពីកាលបរិច្ឆេទត្រូវបង់បុព្វលាភបន្ទាប់
នៅពេលដែលអ្នកត្រូវបានធានារ៉ាប់រងទទួលរងពិការភាព
ទាំងស្រុង និងជាអចិន្ត្រៃយ៍ ឬធ្វើរោគវិនិច្ឆ័យរកឃើញ/
ការវះកាត់ជាក់ស្តែងនូវជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់ណាមួយដូច
បានចែងក្នុងខ និងលក្ខខណ្ឌនៃបណ្ណសន្យារ៉ាប់រង។

## ជម្រើសទី៣

ករណីម្ចាស់បណ្ណសន្យារ៉ាប់រងទទួលមរណភាព ពិការភាព
ទាំងស្រុង និងជាអចិន្ត្រៃយ៍ ឬមានជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់

ក្រុមហ៊ុននឹងលើកលែងនូវការបង់បុព្វលាភធានារ៉ាប់រង
ចាប់ពីកាលបរិច្ឆេទត្រូវបង់បុព្វលាភបន្ទាប់
នៅពេលដែលម្ចាស់បណ្ណសន្យារ៉ាប់រងទទួលមរណភាព
ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ឬធ្វើរោគវិនិច្ឆ័យ
រកឃើញ/ការវះកាត់ជាក់ស្តែងនូវជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់
ណាមួយដូចបានចែងក្នុងខ និងលក្ខខណ្ឌនៃបណ្ណសន្យារ៉ាប់រង។

ចំណាំ៖ ខ្លឹមសារក្នុងខិត្តប័ណ្ណផ្សព្វផ្សាយនេះគឺជាការពណ៌នាដោយសង្ខេប។ សម្រាប់ព័ត៌មានលម្អិតនៃការធានារ៉ាប់រង រួមមានអត្ថប្រយោជន៍ធានារ៉ាប់រង ករណីមិនធានា និងលក្ខខណ្ឌនៃការបញ្ចប់កិច្ចសន្យា សូមអានខ និងលក្ខខណ្ឌធានារ៉ាប់រង។

# I ករណីមិនធានា

**១. មរណភាព**
ករណីផ្សេងៗដូចបានចែងក្នុង "ករណីមិនធានា" នៃផលិតផលមូលដ្ឋាន។

**២. ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍**
ករណីផ្សេងៗដូចបានចែងក្នុង "ករណីមិនធានា" នៃផលិតផលមូលដ្ឋាន។

**៣. ជំងឺធ្ងន់ធ្ងរ**
(១) ជំងឺដែលបណ្តាលមកពីជំងឺអេដស៍ ភាពស្មុគស្មាញទាក់ទងនឹងជំងឺអេដស៍ ឬការបង្ករោគដោយវីរុសហ៊ីវ (HIV)។
(២) ស្ថានភាពដែលមានពីមុនស្រាប់ មុនកាលបរិច្ឆេទដែលបណ្ណសន្យារ៉ាប់រងមានសុពលភាព ឬកាលបរិច្ឆេទនៃការបន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញ ដោយយកកាលបរិច្ឆេទចុងក្រោយគេ។ ស្ថានភាពដែលមានពីមុនស្រាប់ មានន័យថាជាជំងឺដែលអ្នកត្រូវបានធានារ៉ាប់រងបានដឹងច្បាស់ លុះត្រាតែស្ថានភាពទាំងនោះត្រូវបានប្រកាសមកកាន់ក្រុមហ៊ុន និងទទួលយកដោយក្រុមហ៊ុន។ អ្នកត្រូវបានធានារ៉ាប់រងអាចត្រូវបានចាត់ទុកថាបានដឹងច្បាស់អំពីស្ថានភាពដែលមានពីមុនស្រាប់ ប្រសិនបើមានស្ថានភាពណាមួយដូចបានចែងខាងក្រោម៖
- ក) អ្នកត្រូវបានធានារ៉ាប់រងបានទទួល ឬកំពុងទទួលការព្យាបាល
- ខ) យោបល់វេជ្ជសាស្ត្រ ការធ្វើរោគវិនិច្ឆ័យ ការថែទាំ ឬការព្យាបាលផ្នែកវេជ្ជសាស្ត្រត្រូវបានណែនាំ
- គ) មានរោគសញ្ញាច្បាស់ និងជាក់លាក់ត្រូវបានបង្ហាញ
- ឃ) វត្តមាននៃស្ថានភាពនោះអាចមើលឃើញដោយបុគ្គលធម្មតាក្នុងកាលៈទេសៈណាមួយ។

(៣) ការប៉ុនប៉ងធ្វើអត្តឃាត ឬធ្វើឲ្យរបួសខ្លួនឯង ទោះស្ថិតក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមិនប្រក្រតីក៏ដោយ។
(៤) អ្នកត្រូវបានធានារ៉ាប់រងស្ថិតនៅក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ឬការប្រើប្រាស់ថ្នាំណាមួយ លើកលែងតែស្ថិតក្រោមការណែនាំរបស់គ្រូពេទ្យដែលមានអាជ្ញាបណ្ណត្រឹមត្រូវ។
(៥) ជំងឺធ្ងន់ធ្ងរទាំងអស់ដែលមានស្រាប់ ឬធ្វើរោគវិនិច្ឆ័យរកឃើញក្នុងរយៈពេលរង់ចាំដោយរាប់បញ្ចូលទាំងជំងឺធ្ងន់ធ្ងរកម្រិតដំបូង ដែលត្រូវបានរកឃើញពេលធ្វើរោគវិនិច្ឆ័យដំបូងក្នុងរយៈពេលរង់ចាំ ហើយវិវត្តទៅជាជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់បន្ទាប់ពីរយៈពេលរង់ចាំត្រូវបានផុតកំណត់។
(៦) សង្គ្រាម ឬសកម្មភាពពាក់ព័ន្ធនឹងសង្គ្រាម (មិនថាបានប្រកាស ឬមិនបានប្រកាស) ការធ្វើកូដកម្ម ចលនាបះបោរ បដិវត្តន៍ សង្គ្រាមស៊ីវិល សកម្មភាពភេរវកម្មមិនថាអ្នកត្រូវបានធានារ៉ាប់រងចូលរួម ឬមិនចូលរួមក្តី។
(៧) ការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ឬការប៉ុនប៉ងក្នុងការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌដោយម្ចាស់បណ្ណសន្យារ៉ាប់រង អ្នកត្រូវបានធានារ៉ាប់រង ឬអ្នកទទួលផល។ អ្នកទទួលផលដែលមិនបានចូលរួមពាក់ព័ន្ធក្នុងសកម្មភាពបទល្មើសព្រហ្មទណ្ឌ ដែលបានរៀបរាប់ខាងលើនឹងនៅតែមានសិទ្ធិទទួលបានអត្ថប្រយោជន៍របស់ពួកគេដដែល។
(៨) ប្រសិនបើមានផលប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលពីការសារធាតុវិទ្យុសកម្មដែលកើតឡើងពីឥន្ធនៈ អាវុធ កាកសំណល់ ឬការកែច្នៃ។
(៩) ការធ្វើដំណើរចូល ការចាកចេញ ការប្រតិបត្តិការ ការផ្តល់សេវា ឬត្រូវបានបញ្ជូនដោយយាន ឬមធ្យោបាយធ្វើដំណើរតាមផ្លូវអាកាស លើកលែងតែក្នុងករណីអ្នកត្រូវបានធានារ៉ាប់រងគឺជាអ្នកដំណើរបង់ប្រាក់ធម្មតា ឬអ្នកបម្រើការលើយន្តហោះនៃក្រុមហ៊ុនអាកាសចរណ៍ពាណិជ្ជមួយ ដែលធ្វើការជាប្រចាំ និងទៀងទាត់តាមកាលវិភាគ និងគន្លងធ្វើដំណើរផ្លូវអាកាសដែលបានកំណត់របស់ក្រុមហ៊ុន។
(១០) ការចូលរួមក្នុងសកម្មភាពកីឡាគ្រោះថ្នាក់រួមមាន តែមិនកំណត់ត្រឹមការជ្រមុជទឹក ការឡើងភ្នំ ការលោតឆ័ត្រយោង ឬការប្រណាំងល្បឿនលឿនណាមួយ ឬសកម្មភាពកីឡាអាជីព។